ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១១៣១ ....សហវ.[illegible]

ថ្ងៃ ដប់ពីរកើត ខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស២៥៦៩
រាជធានីភ្នំពេញ,ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០២៥

# ប្រកាស
## ស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូល និងការបែងចែកឥណទានចំណាយថវិការាជធានី ខេត្ត ជូនខេត្តបន្ទាយមានជ័យ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលថ្មីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៥ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២៥/០៤០ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ ២៥៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនិងតាមកម្មវិធីនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦
- បានឃើញអនុក្រឹត្យលេខ ២៥៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការផ្ទេរឥណទានថវិកា
- បានឃើញប្រកាសលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីបទបញ្ជាថវិការបស់ខេត្ត ក្រុង
- បានឃើញសារាចរណែនាំលេខ ០២២ សហវ.សរណ.អហក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ ១.**_

ចំណូល ចំណាយថវិការបស់ខេត្តបន្ទាយមានជ័យសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ រួមមាន:

- **សរុបចំណូល: ៦៤ ៨៥៦ ០០០ ០០០ រៀល** (ហុកសិបបួនប៊ីលានប្រាំបីរយហាសិបប្រាំមួយលានរៀលគត់) ក្នុងនោះចំណូលកាតព្វកិច្ចផ្ទាល់របស់ខេត្ត ចំនួន ៦១ ១៥៦ ០០០ ០០០ រៀល និងឧបត្ថម្ភធនពីថវិកាថ្នាក់ជាតិ ចំនួន ៣ ៧០០ ០០០ ០០០ រៀល

- **សរុបចំណាយ: ៣៦ ៨៩៨ ០០០ ០០០ រៀល** (សាមសិបប្រាំមួយប៊ីលានប្រាំបីរយកៅសិបប្រាំបីលានរៀលគត់) នឹងត្រូវបែងចែកទៅតាមចំណាត់ថ្នាក់ចំណូល ចំណាយថវិការាជធានី ខេត្ត តាមជំពូក គណនី និងអនុគណនី ដូចមាននៅក្នុងសៀវភៅថវិកាដែលភ្ជាប់នឹងប្រកាសនេះ

- **អតិរេកថវិកា ចំនួន ២៧ ៩៥៨ ០០០ ០០០ រៀល** ត្រូវបង់ចូលថវិកាថ្នាក់ជាតិសម្រាប់បែងចែកសារឡើងវិញដោយកត់ត្រាបន្ថែមឥណទានថវិកាជំពូក ៦៥ គណនី ៦៥០១ និងអនុគណនី ៦៥០១១ ឧបត្ថម្ភធនដល់រាជធានី ខេត្ត។

**ប្រការ២.**_

អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបន្ទាយមានជ័យ ប្រធានរតនាគារខេត្តបន្ទាយមានជ័យ និងប្រធានមន្ទីរជំនាញពាក់ព័ន្ធជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ។

**ប្រការ៣.**_

ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៦ នេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ